**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងមុខងារសាធារណៈ**
លេខ : មស.

## សារលិខិតជូនពរ

**សូមគោរពជូន**
**ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត អ៊ឹម ឈុនលឹម ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ**

**ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ជាទីគោរពដ៏ខ្ពង់ខ្ពស់**!

ក្នុងឱកាសនៃពិធីបុណ្យចូលឆ្នាំសកល ឆ្នាំ២០២២ ខាងមុខនេះ ខ្ញុំបាទនិងថ្នាក់ដឹកនាំ ព្រមទាំងមន្ត្រីរាជការទាំងអស់នៃក្រសួងមុខងារសាធារណៈ សូមលើកហត្ថប្រណាមបួងសួងដល់គុណបុណ្យព្រះរតនត្រ័យ កែវទាំងបី វត្ថុស័ក្តិសិទ្ធិទាំងអស់ក្នុងលោក និងទេវតារក្សាទឹកដី នៃព្រះរាជាណាចក្រកម្ពុជា សូមព្រះអង្គតាមជួយបីបាច់ថែរក្សា ប្រោះព្រំ ប្រទានពរជ័យ សិរីសួស្តី បវរមហាប្រសើរជូន **ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត និងលោកជំទាវ**។

ក្នុងឱកាសដ៏មហាប្រសើរថ្លៃថ្លានេះដែរ យើងខ្ញុំទាំងអស់គ្នាសូមសម្តែងនូវមនោសញ្ចេតនាគោរពនិងដឹងគុណដោយស្មោះអស់ពីដួងចិត្តចំពោះទឹកចិត្តដ៏ថ្លៃថ្លា និងសកម្មភាពដ៏ឧត្តុង្គឧត្តមរបស់ **ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត** ក្នុងបេសកកម្មដឹកនាំស្ថាប័នក្រុមប្រឹក្សាធម្មនុញ្ញ ដើម្បីបុព្វហេតុបម្រើជាតិមាតុភូមិកម្ពុជា តាមរយៈការធានាធម្មនុញ្ញភាព និងនីតិរដ្ឋនៅកម្ពុជា សំដៅចូលរួមចំណែកយ៉ាងសំខាន់ក្នុងឧត្តមប្រយោជន៍ជាតិនិងប្រជាជននៅទូទាំងប្រទេស។

ឆ្លៀតក្នុងឱកាសដ៏រីករាយនិងថ្លៃថ្លានេះ យើងខ្ញុំទាំងអស់គ្នា សូមបួងសួងដល់គុណបុណ្យព្រះរតនត្រ័យ និងវត្ថុស័ក្តិសិទ្ធិទាំងអស់ក្នុងលោក សូមប្រោសប្រទានជូន **ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត និងលោកជំទាវ ព្រមទាំងបុត្រាបុត្រី និងចៅប្រុស ចៅស្រី** សូមមានសុខភាពល្អបរិបូរណ៍ និងទទួលបាននូវព្រះពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូម **ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ និងជ្រាលជ្រៅបំផុតពីយើងខ្ញុំទាំងអស់គ្នា។

ថ្ងៃ ពុធ ៣ រោច ខែ មិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ២០២១

**តំណាងថ្នាក់ដឹកនាំនិងមន្ត្រីរាជការ នៃក្រសួងមុខងារសាធារណៈ**
**រដ្ឋមន្ត្រី**

ហ៊ុំ-សុខា

ផ្លូវវត្តអង្គតាមិញ ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ/ទូរសារ : +៨៥៥-២៣-៨៦៦៥០១/+៨៥៥-២៣-៨៦៦៥០៥ | គេហទំព័រ : http://www.mcs.gov.kh